# ការណែនាំអំពីការដំឡើង
# DRC-011



# I. សេចក្តីផ្តើម

ឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-011 គឺជាឧបករណ៍បញ្ជាឆ្លាតវៃសម្រាប់បំពាក់ជាមួយ Auto Recloser ENTEC ដើម្បីបញ្ជា និងត្រួតពិនិត្យទិន្នន័យពីចម្ងាយ ។ ឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-011 ប្រើប្រាស់ GSM/GPRS សម្រាប់ទំនាក់ទំនង ត្រួតពិនិត្យ និងបញ្ជាតាមរយៈកម្មវិធីស្មាតហ្វូន (Android) និង RPM Grid (PC) ។ DRC-011 ផ្តល់ភាពងាយស្រួល និងអនុញ្ញាតឲ្យក្រុមការងារបច្ចេកទេសអគ្គិសនីអាចគ្រប់គ្រង បញ្ជា និងត្រួតពិនិត្យបណ្តាញអគ្គិសនីតង់ស្យុងមធ្យម ២២ kV និង ៣៥ kV ប្រកបទៅដោយប្រសិទ្ធភាពខ្ពស់ ។

# II. គ្រឿងបរិក្ខារ




ឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-011 ចំនួន ១



ជើងទម្រឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-011 ចំនួន ១



អង់តែន GSM ចំនួន ១



ខ្សែបញ្ជូនទិន្នន័យ (Male to Female) ចំនួន ១



ខ្សែភ្លើងចរន្តជាប់ ចំនួន ១



ខ្សែចំណងជ័រ ចំនួន ៦



វីសមានក្បាលខ្មៅ ចំនួន ២

# III. ការដំឡើង

## សម្ភារសម្រាប់ដំឡើង



អូមម៉ែត្រ



ទួណឺវីសមុខ ៤



ដង្កាប់កាត់ខ្សែភ្លើង

## ដំណើរការដំឡើង DRC-011

**01** បំពាក់ជើងទម្រឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-011 នៅក្នុងទូបញ្ជា ENTEC ។



**02** បំពាក់ឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-011 នៅលើជើងទម្រ ។




**03** វាស់តង់ស្យុងចរន្តជាប់រវាង 1 VCC នឹង 2 AGND ដោយប្រើប្រាស់អូមម៉ែត្រ ។




**ចំណាំ**

- តង់ស្យុងសម្រាប់ដំណើរការ ចន្លោះពី 12-36 Vdc ។

**04** ភ្ជាប់ខ្សែភ្លើងចរន្តជាប់ DC ដោយខ្សែពណ៌ក្រហមទៅ 1 VCC និងខ្សែពណ៌ខ្មៅទៅ 2 AGND ។



**05** ដោតខ្សែភ្លើងចរន្តជាប់ទៅក្នុងរន្ធ 24V ដែលស្ថិតនៅលើឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-011 ចំហៀងខាងស្តាំ ។



**06** ភ្ជាប់ខ្សែបញ្ជូនទិន្នន័យ (Female) ជាមួយនឹង SERIAL PORT 1 នៅលើទូបញ្ជា ENTEC ។




**07** ភ្ជាប់ខ្សែបញ្ជូនទិន្នន័យ (Male) ជាមួយនឹង RS232 នៅលើ ឧបករណ៍បញ្ជាផ្ដាច់ភ្ជាប់ពីចម្ងាយ DRC-011 ។




**08** ដាក់បញ្ចូលស៊ីមកាត ក្នុងរន្ធដាក់ស៊ីមកាតនៅលើ ឧបករណ៍បញ្ជាផ្ដាច់ភ្ជាប់ពីចម្ងាយ DRC-011 ។



**⚠ ចំណាំ**

- ទីតាំង អង់តែន GSM ត្រូវតែដាក់នៅទីតាំងដែលអាចទទួលសេវាបានល្អ ។

**09** ភ្ជាប់ខ្សែអង់តែន GSM ទៅកាន់រន្ធ ANT នៅលើ ឧបករណ៍បញ្ជាផ្ដាច់ភ្ជាប់ពីចម្ងាយ DRC-011 ។




**10** ដាក់បញ្ចូលស៊ីមកាត ក្នុងរន្ធដាក់ស៊ីមកាតនៅលើ ឧបករណ៍បញ្ជាផ្ដាច់ភ្ជាប់ពីចម្ងាយ DRC-011 ។



**11** ចុចប៊ូតុងដើម្បីបើកភ្លើងដំណើរការឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-011 ។




## ⚠ ចំណាំ

- ឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-011 ដំណើរការធម្មតា Running LED ភ្លឹបភ្លែតៗ រៀងរាល់ ១ វិនាទី ។
- សេវា GSM (GSM Connection) ដែលធ្វើការត្រឹមត្រូវ Net LED ភ្លឹបភ្លែតៗ រៀងរាល់ ៣ វិនាទី ។
- GSM Module ដំណើរការធម្មតា GSM LED ភ្លឺជាប់ ។

**12** ចុចបើក REMOTE ENABLED ។



sale@vpstart.com | info@vpstart.com (+855) 23 888 167 | (+855) 86 666 677